ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៨៥២
ចុះថ្ងៃទី ០៨-៨-២០០៩
សាលដីកា
លេខ: ៣៦ ក្រIV.អ
ចុះថ្ងៃទី ០៦-៣-២០១២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំនុំជំរះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នា ថ្ងៃទី០៦-៣-២០១២ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជំរះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៨៥២ ចុះថ្ងៃទី ០៨-៨-២០០៩ រវាង:

- ជនជាប់ចោទឈ្មោះ [redacted]ខេមរិន្ទ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី៦ថ្មី មុខរបរធ្វើស្រែ កើតនៅជំរុំជាយតែព្រំដែនខ្មែរ-ថៃ ទីលំនៅសព្វថ្ងៃ[redacted] ខេត្តបាត់ដំបង ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ។

- មេធាវីការពារជនជាប់ចោទលោក នូ ចន្ថា ។

ជាប់ចោទពីបទ: ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិដូនមាយ ឃុំស្នោ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង កាលពីថ្ងៃទី១៣-១២-២០០៨ ត្រូវផ្តន្ទាទោសតាមបញ្ញតិមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ាន ភេទស្រី អាយុ៨៨ឆ្នាំ រស់នៅភូមិដូនមាយ ឃុំស្នោ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។

## អង្គហេតុ

កាលពីថ្ងៃទី១៣-១២-២០០៨ វេលាម៉ោងប្រហែល ០៥.៣០នាទីទៀបភ្លឺ នៅចំណុចភូមិដូនមាយ ឃុំស្ដៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង មានករណីឃាតកម្មគិតទុកជាមុនមួយកើតឡើង ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] ខេមរិទ្ធ ដែលបានសម្លាប់ប្រពន្ធរបស់ខ្លួន[redacted]សារុំ នៅផ្ទះ ។

- តាមចម្លើយជនជាប់ចោទឈ្មោះ[redacted]ខេមរិទ្ធ បានឆ្លើយថា៖ ថ្ងៃនោះខ្លួនសួរប្រពន្ធថា អាអូនបាត់ក្ដៅខ្លួនហើយឬនៅ ប្រពន្ធខ្លួនឆ្លើយថានៅ រួចខ្លួនយកកូនឲ្យម្ដាយមើល ពេលដើរទៅ ខ្លួនឃើញមនុស្សម្នាក់ពាក់អាវខៀវ នៅមុខប៉ូលីសខ្លួនឆ្លើយអញ្ចឹង ។ ពេលកំពុងច្រូតស្រាប់តែឈ្មោះ សុវណ្ណា ថាម៉េចមិនទៅមើលប្រពន្ធដេកសន្លប់នៅផ្ទះ ។ នៅយប់នោះខ្លួនពុំបានឈ្លោះជាមួយប្រពន្ធទេ មុនថ្ងៃនោះខ្លួនផឹកស៊ីមិនមានឈ្លោះជាមួយប្រពន្ធទេ ។ ខ្លួនរៀបការនៅឆ្នាំ២០០៧ ។ ខ្លួនស្រឡាញ់ប្រពន្ធមែន ចំពោះឈ្មោះ[redacted]សារៀម ខ្លួនពុំបានស្រឡាញ់ទេ ហើយក៏ពុំបានស្រឡាញ់ ឬបបួលឈ្មោះ[redacted]សារ័ត្ន ទៅប្រទេសថៃដែរ ។ ខ្លួនសុំបដិសេធចំពោះពាក្យថា ខ្លួនស្រឡាញ់ប្អូនថ្លៃស្រីរបស់ខ្លួនឈ្មោះ[redacted]សារៀម ។ ខ្លួនចេញពីផ្ទះប្រហែលម៉ោង ៥.៣០នាទីព្រឹក ទៅម៉ោង ៦ព្រឹក ខ្លួនមិនឲ្យប្រពន្ធយកកូនទៅឲ្យម្ដាយខ្លួនទេ ពីព្រោះវាក្មេង ។ ម្ដាយបង្កើតខ្លួនឈ្មោះ[redacted]យៀម ។ ចំពោះឥវ៉ាន់នោះខ្លួនចងជាមួយប្អូនថ្លៃខ្លួន ។ ខ្លួនសង្ស័យមនុស្សម្នាក់សក់វែង ។ កាំបិតខ្វែវនោះ ខ្លួនយកពីឪពុកខ្លួនមកយូរហើយ ម្ដងទុកក្រោមផ្ទះ ម្ដងទុកលើផ្ទះ ពេលខ្លួន និងប្រពន្ធនាំកូនទៅពេទ្យនោះប្រហែល ៧គីឡូម៉ែត្រ ។ ថ្ងៃទី១៣ ខ្លួនយកកូនទៅឲ្យម្ដាយ ពីព្រោះខ្លួនឲ្យប្រពន្ធនៅចាំផ្ទះ និងដាំបាយ មុនកើតហេតុ ០១ថ្ងៃ ម្ដាយខ្លួនទៅច្រូតថ្ងៃនោះវាក្ដៅខ្លួន ហើយខ្លួនឲ្យលេបតាមវេជ្ជបញ្ជាដែរ ។ ថ្ងៃទៅច្រូតនោះ ប្រពន្ធខ្លួនពុំទៅទេ ពេលដេកវាស្លៀកសារ៉ុង និងខោក្នុងធម្មតា ។

- កំនត់ហេតុសួរចម្លើយជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ បានឆ្លើយថា៖ នៅថ្ងៃទី១២-១២-២០០៨ វេលាម៉ោងប្រហែល ៧យប់ ខ្លួនមានគ្នា ៣នាក់ ផឹកស្រានៅផ្ទះរបស់ខ្លួន ហើយបែកគ្នានៅម៉ោង ៨យប់ ។ ដល់ម៉ោងប្រហែល ៥.៣០នាទី ទៀបភ្លឺ ខ្លួនក្រោកពីដំណេករួចយកកូន អាយុ០១ឆ្នាំ យកទៅផ្ញើម្ដាយបង្កើតរបស់ខ្លួន រួចដើរទៅច្រូតស្រូវបានប្រហែល ៧-៨ កណ្ដាប់ ស្រាប់ឈ្មោះ[redacted] សុវណ្ណា ជាអ្នកជិតខាងមកប្រាប់ថា ប្រពន្ធខ្លួនស្លាប់ហើយ ពេលទៅដល់ខ្លួនដោះអាវពណ៌ក្រហមយឺតដៃវែង យកទៅជូតឈាម ហើយឈាមដែលស្ងួត ខ្លួនយកដៃកេសចេញពីមុខ ហើយចាប់អង្អែលដៃ និងមុខប្រពន្ធខ្លួន ។ កន្លងមកខ្លួនពុំ ដែលភ្ញាក់ពីដំណេកទៅធ្វើការទាំងព្រឹកទេ ដល់ថ្ងៃកើតហេតុខ្លួនទៅធ្វើការពីព្រឹក ដោយសារយកកូនទៅជាមួយដើម្បីឲ្យម្ដាយជួយមើល ។ នៅខែកក្កដាឆ្នាំ២០០៨ ម៉ោងប្រហែល ០១រសៀល ខ្លួនបានទៅដួសត្រីនៅស្ទឹងខាងត្បូងភូមិដូនមាយជាមួយប្អូនថ្លៃស្រីឈ្មោះ [redacted] សារៀម ពេលនោះខ្លួនបាននិយាយសុំស្រឡាញ់ប្អូនថ្លៃស្រី

ព្រមទាំងបបួលទៅរស់នៅចាំ ចំការឲ្យថៃ ដោយប្រាប់ថា បានកូន១ទើបត្រឡប់មកវិញ ប៉ុន្តែប្អូនថ្លៃខ្លួនប្រកែក ពេលមកដល់ផ្ទះវិញ ប្អូនថ្លៃខ្លួនបានយករឿងនេះប្រាប់ប្រពន្ធខ្លួន ហើយប្រពន្ធខ្លួនស្តីបន្ទោសខ្លួន ហើយខ្លួនក៏ទទួលកំហុស ។ (ឯ.១៥)

- តាមកំណត់ហេតុយកចម្លើយឈ្មោះ [redacted] យឿម បានឆ្លើយថា៖ កាលពីព្រឹកថ្ងៃកើតហេតុកូនប្រុសរបស់ខ្លួន បានយកកូនរបស់វាមកអោយខ្លួនមើលអោយរួចចេញទៅច្រូតបាត់ទៅ ។ ឈ្មោះ [redacted] ខេមរិន្ទ យកកូនមកផ្ញើថា ផ្ញើមួយភ្លែតចាំប្រពន្ធវាឈ្មោះ [redacted] សារុំ មកតាមក្រោយនឹងយកកូនទៅពេទ្យ ដោយអោយបងថ្លៃ ដែលមានម៉ូតូជូនទៅ ។ ក្រោយពីបានទទួលចៅហើយខ្លួនបានបញ្ចុកបបរ ។ បញ្ចុករួច ខ្លួនយកចៅទៅអោយម្តាយវាវិញ ដើម្បីអោយចៅលេបថ្នាំ ។ ពេលយកចៅទៅអោយម្តាយវាវិញនោះ ខ្លួនបានហៅម្តាយវាពុំឆ្លើយ ខ្លួនក៏ចូលមើល ស្រាប់តែឃើញឈ្មោះ [redacted] សារុំ ដេកនៅលើផ្ទះពុំមានសំលៀកបំពាក់ទេ ខ្លួនក៏ចេញមកវិញ ហើយស្រែកហៅអោយគេជួយ ។ (ឯ.៣៤)

- អ្នកបំភ្លឺឈ្មោះ [redacted] លឹមសឺន បានបញ្ជាក់នាពេលសវនាការថា នៅពេលសួរចម្លើយជនជាប់ចោទ មិនបានគម្រាមជននេះទេ មុនដំបូងខ្លួនទៅពិនិត្យសាកសពមិនមែនត្រូវគេរំលោភទេ ហើយខ្លួនពិនិត្យពីការប្លន់តែពុំមានបាត់របស់ទេ ដូចនេះវាជារឿងគំនុំរួចខ្លួនធ្វើការសាកសួរ និងប្រមូលភស្តុតាង ។ ពេលសួរលើកទី១ ឈ្មោះ [redacted] ខេមរិន្ទ ពុំបានឆ្លើយថា ស្រឡាញ់ទេ ។ មុនដំបូងសង្ស័យថា គេរំលោភ តែពេលពិនិត្យមិនឃើញដូច្នេះទេ ខ្លួនពុំសង្ស័យលើករណីរំលោភទេ ព្រោះមិនមានការស្រែក ប្តីរបស់ជនរងគ្រោះចេញបាន ១០០ម៉ែត្រមែន ខ្លួនមិនថាជនល្មើសវាយជនរងគ្រោះទេ ។ តាមស្ថានភាពសពដូចជាត្រូវគេរំលោភ ហើយទើបសម្លាប់ តែពេលពិនិត្យ មិនឃើញមានទឹកកាមប្រឡាក់ទេ ពេលនោះប្តីរបស់សពនៅតែអង្អែលសព ។ ខ្លួនទៅដល់កន្លែងសាកសពនៅម៉ោង ៨ព្រឹក ។

- អ្នកបំភ្លឺឈ្មោះ [redacted] ជំនិត បានបញ្ជាក់នាពេលសវនាការថា ពេលខ្លួនទៅពិនិត្យសាកសពនោះ គឺស្លាប់នៅម៉ោង ៦ព្រឹក ។ តាមការពិនិត្យឃើញសាកសពមុខរបួសខាងក្នុងនៅឈាមរាវ ហើយយើងពិនិត្យទឹកកាមមិនមានសពស្លាប់ដោយសារគេអារកដាច់បំពង់ខ្យល់ នៅលើមុខសាកសពមានស្នាមជាំ វត្ថុតាងដែលមានការសង្ស័យលើកាំបិតង៉ុកមានឈាមប្រឡាក់ដងកាំបិត ហើយថ្លៃមានស្នាមលាងនៅជិតពាងទឹកមានចង្កៀងដូង ។ ខ្លួនទៅដល់ផ្ទះសាកសពនៅម៉ោង ៨ព្រឹក អ្នកណាឃើញខ្លួននៅម៉ោង ៩ ខ្លួនមិនដឹងទេ គឺខ្លួនទៅម៉ោង ៨ព្រឹក ។ ខ្លួនមិនបានស្ទាបកំដៅសាកសពទេ តែខ្លួនប៉ះសពទៅវាត្រជាក់ ខ្លួនពុំបានពិនិត្យក្រយៅដៃទេ ចំពោះឈាមកកនោះអាចមនុស្សនោះសន្លប់ទើបគេអារក ពេលខ្លួនធ្វើដំណើរទៅបានជួបប្អូនស្រីជនរងគ្រោះដែរ ។ ខ្លួនបានបាចម្សៅ ក្រយៅដៃដែរ តែយកក្រយៅដៃពុំបានទេ ពីព្រោះរញ៉េរញ៉ៃ។

- តាមកំណត់ហេតុសួរចម្លើយឈ្មោះ [redacted] សារ័ត្ន បានឆ្លើយថា កាលពីថ្ងៃទី១៣-១២-២០០៨ ម៉ោងប្រហែល ៨កន្លះ ខ្លួនបានទទួលដំណឹងថា ប្អូនស្រីខ្លួនឈ្មោះ [redacted] សារុំ ត្រូវគេ



CamScanner

សម្លាប់ ក្រោយពីបានទទួលដំណឹងនេះខ្លួនទៅមើល ឃើញថាពិតជាស្លាប់មែន ។ អ្នកណាសម្លាប់នោះខ្លួនមិនដឹងទេ តែសង្ស័យឈ្មោះ [redacted] ខេមរិន្ទ ជាប្តីរបស់ឈ្មោះ ជុំ សារុំ ដោយសារប្អូនស្រីខ្លួនពុំដែលមានទំនាស់ជាមួយអ្នកណាទេ ហើយប្តីប្រពន្ធនេះឧស្សាហ៍ឈ្លោះគ្នា ។ (ឯ.៣០)

- តាមកំណត់ហេតុសួរចម្លើយឈ្មោះ [redacted] សារឿម បានឆ្លើយថា កាលពីថ្ងៃទី១៣-១២-២០០៨ វេលាម៉ោង ៨ព្រឹក ឈ្មោះ [redacted] ជាត ភេទស្រីបានប្រាប់ខ្លួនថា បងស្រីខ្លួនឈ្មោះ [redacted] សារុំ សន្លប់ហើយ តែពេលទៅដល់គាត់ដេកស្លាប់នៅលើផ្ទះគាត់ ។ ពេលទៅដល់នោះមានគេទៅមើលមុនហើយ ។ សាកសពមានគេគ្របអាវលើខ្លួន ត្រឹមចង្កេះចុះក្រោម ខ្លួនមិនបានចាំថា មានស្លៀកសំពត់ ឬគ្របសំពត់ទេ ។ ពេលខ្លួនទៅមើលនោះឈ្មោះ [redacted] ខេមរិន្ទក៏នៅទីនោះដែរ ។ កន្លែងស្លាប់នៅក្រៅ ពីកន្លែងដេកធម្មតារបស់គាត់ ។ លុះម៉ោងប្រហែល ៩ព្រឹក ទើបប៉ូលីសទៅដល់ ហើយធ្វើការពិនិត្យ ។ ឈ្មោះ [redacted] ខេមរិន្ទ ធ្លាប់និយាយសុំស្រឡាញ់ខ្លួន កាលពីខែឧសភា ឆ្នាំ២០០៨ និងធ្លាប់បបួលខ្លួនទៅប្រទេសថៃតែខ្លួនមិនព្រម ។ ហើយធ្លាប់និយាយប្រាប់ខ្លួនថា គាត់អស់និស្ស័យនឹងបងស្រីរបស់ខ្លួនទៀតហើយ ឈ្មោះ [redacted] ខេមរិន្ទ ក៏ធ្លាប់បបួលខ្លួនទៅយកអាគុយនៅកន្លែងសាក តែគាត់អោយខ្លួនឱបហើយ គាត់ជិះពីក្រោយសុំអោបខ្លួនតែខ្លួនមិនព្រម ។ ខ្លួនបានយករឿងទាំងអស់ប្រាប់បងស្រីខ្លួនជាប្រពន្ធគាត់ ហើយគាត់ឈប់និយាយរកខ្លួន ហើយខ្លួនក៏ឈប់និយាយរកគាត់វិញដែរ រហូតដល់ថ្ងៃបងស្រីខ្លួនស្លាប់ ។ (ឯ.៣១)

- សាក្សីឈ្មោះ [redacted] ណាត បានបញ្ជាក់នាពេលសវនាការថា ពេលឈ្មោះ ខេមរិន្ទ យកកូនវាទៅអោយខ្លួនម៉ោងជាង ៦ព្រឹក ខ្លួនដាំបបរឆ្អិនស្រេចបាច់ហើយ ខ្លួនយកកូនទៅអោយម៉ែវាវិញ ដើម្បីទៅច្រូតដែរ ពេលយកកូនវាទៅកាន់ចេក១ ទៅដែរ ខ្លួនដើរទៅផ្ទះវានោះ ជាងកន្លះម៉ោង ហើយចេញទៅនោះម៉ោងជាង ៧ព្រឹក មិនទាន់ឃើញអ្នកណាម្នាក់ទេនៅពេលនោះ ។ ពេលឃើញសាកសពនោះ កូនស្រីខ្លួន (ជនរងគ្រោះ) ដេកស្រាត ខោលីអូនៅចុងជើង ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨៧(ជ) ចុះថ្ងៃទី២៥-៦-២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា:

១/ ក- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ខេមរិន្ទ ភេទប្រុស អាយុ២៥ឆ្នាំ (មានសាវតាជាតិខាងលើ) កំណត់ដាក់ពន្ធនាគាររយៈពេល ២០(ម្ភៃ)ឆ្នាំ គិតចាប់ពីថ្ងៃឃាត់ខ្លួន ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៨ ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិដូនម៉ាយ ឃុំស្ពៅ ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៨ តាមបញ្ញត្តិមាត្រា ០៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

ខ- បង្គាប់អោយឈ្មោះ [redacted] ខេមរិន្ទ សងសំណង និងជម្ងឺចិត្ត គិតជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន)រៀល ទៅអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ គង់ វ៉ាន គិតចាប់

ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។ ដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងសុំ លើសពីនេះត្រូវបដិសេធចោល ។

២/ វត្ថុតាងដែលជាកាំបិតខ្មែរ (កាំបិតដុំក) ដងឈើ ផ្លែខ្មៅ ចំនួន ០១ (មួយ) ដើម ត្រូវរឹបអូស និងបំផ្លាញចោល ។

៣- សាលក្រមនេះជំនុំជម្រះសម្រេចសេចក្ដីចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២០-៧-២០០៩ របស់ឈ្មោះ សួន ខេមរិទ្ធ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៧(ជ) ចុះថ្ងៃទី២៥-៦-២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុច ទាំងមូលនៃសាលក្រម ។

- បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី១៦-២-២០១០ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

- បានឃើញ សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី១៤-៧-២០១០ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**<u>នាពេលសវនាការ</u>**

- ជនជាប់ចោទឈ្មោះ សួន ខេមរិទ្ធ (អវត្តមាន)
- មេធាវីការពារជនជាប់ចោទលោក នូ ចន្ថា (វត្តមាន)
- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ គង់ ភ៉ន (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍ និងសង្ខេបរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទ និងដើមបណ្ដឹង

<u>តំណាងមហាអយ្យការសន្និដ្ឋានថា</u>

- ក្រោយពីបានស្ដាប់អំណានរបស់ជនជាប់ចោទ និងអំណានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទោះបីជនជាប់ចោទបានប្រកែកក៏តំណាងអយ្យការបានឯកភាពដោយមានភស្តុតាងដាក់បន្ទុក ដោយការផ្ដន្ទាទោស សូមក្រុមប្រឹក្សាពិចារណាទៅលើក្រមថ្មី សុំពិចារណាលើក្រមណាស្រាលជាង ។

- លោក នូ ចន្ថា មេធាវីការពារជនជាប់ចោទសន្និដ្ឋានថា: ក្រោយពីបានស្ដាប់អំណានរបស់ជនជាប់ចោទក្នុងរឿងនេះពិនិត្យឃើញថា ថ្ងៃទី១៣-១២-២០០៨ ពិតជាមានបទព្រហ្មទណ្ឌ ប្រព្រឹត្តមនុស្សឃាតមែន ។ កូនក្ដីខ្លួន ពុំបានប្រព្រឹត្តទេ (តាមចម្លើយកូនក្ដីខ្លួន) កាលដែលសមត្ថកិច្ចចុះទៅពិនិត្យនៅថ្ងៃកើតហេតុ គឺសមត្ថកិច្ចមានសិទ្ធិគ្រប់គ្រាន់ក្នុងការបាញ់ថ្នាំទៅលើសាកសព ជាតុពិតជាក់ស្ដែងថាស្រឡាញ់ប្អូនថ្លៃ គឺប្អូនថ្លៃមានវិធានការណ៍គ្រប់គ្រាន់ មិនអាចអោយទៅសម្លាប់បងស្រីបានទេ ។ សមត្ថកិច្ចបានយកចម្លើយនៅម៉ោង០៨ តែសាក្សីមួយទៀតនៅម៉ោង០៨ដដែល បានប្រាប់កូនក្ដីខ្លួនថា ម៉េចក៏មិនទៅ

មើលប្រពន្ធ ។ ពេលរៀបអាពាហ៍ពិពាហ៍មក កូនក្តីខ្លួនទៅនៅជាច់ដោយឡែកតែពីរនាក់ប្តីប្រពន្ធ ។ នៅកន្លែងកើតហេតុមិនមានអ្វីជាភស្តុតាង ឯចំណុចថានៅពាងទឹកនោះ ក៏គ្មានសាក្សីណាថា កូនក្តីខ្លួនបានលាងកាំបិតទេ ។ តាមមាត្រា ៣៥១ និង ៣៨ វិមតិសង្ស័យត្រូវបានប្រយោជន៍ទៅលើកូនក្តីខ្លួន ។ សំណូមពរ សូមប្រធានប្រឹក្សា និងក្រុមប្រឹក្សាមេត្តាសម្រេចអោយកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់នេះផង ។

- ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង ។
- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ ។
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹង ។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ ។
- ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ។

**<u>សាលាឧទ្ធរណ៍យល់ឃើញថា:</u>**

១- បណ្តឹងឧទ្ធរណ៍លេខ ៩៦ ចុះថ្ងៃទី២០-កក្កដា-២០០៩ របស់ជនជាប់ចោទឈ្មោះ សួន ខេមរិន្ទ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២- មេធាវី ទូ ចន្ថា ជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣-គ្រប់ដំណាក់កាលស៊ើបអង្កេតជនជាប់ចោទឈ្មោះ សួន ខេមរិន្ទ មិនទទួលស្គាល់ថា ខ្លួនជាអ្នកសម្លាប់ប្រពន្ធឈ្មោះ ជុំ សារុំ កាលពីថ្ងៃទី១៣-១២-២០០៨ ម៉ោង ៥.៣០ នាទី ភ្លឺនោះទេ ។

៤- តាំងពីរៀបចំសែនព្រេនឆ្នាំ២០០៧ រវាងឈ្មោះ សួន ខេមរិន្ទ និងនាង ជុំ សារុំ រួចមកទាំងពីរនាក់ មានទំនាស់ញឹកញាប់ ។

៥- ឈ្មោះ សួន ខេមរិន្ទ ធ្លាប់និយាយសុំស្រឡាញ់ប្អូនថ្លៃស្រីឈ្មោះ ជុំ សារ័ត្ន និងឈ្មោះ ជុំ សារឿម នឹងបបួលរត់ទៅនៅប្រទេសថៃ (ឯ.១០, ឯ.១១) ។ ឃើញថា ជនជាប់ចោទមិនស្រឡាញ់ប្រពន្ធស្មោះនោះទេ ។

តាម: វត្ថុចាប់យកមាន:

- កាំបិតជុំកមួយប្រវែង ០.៧៥ម៉ែត្រ មានស្នាមប្រឡាក់ឈាមមួយដំណក់
- ទៅជិតពាងទឹកក្រៅផ្ទះមានស្រកីដូងជូតមុខកាំបិតលាងឈាម
- អាវយឺតដៃវែងពណ៌ក្រហមមានប្រឡាក់ឈាម
- ខោខូវប៊យជើងខ្លីពណ៌ទឹកប៊ិចមានប្រឡាក់ឈាម

ទាំងនេះជាភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ សួន ខេមរិន្ទ ពីបទ មនុស្សឃាតគិតទុកជាមុន កាលពីថ្ងៃទី១៣-១២-២០០៨ នៅភូមិដូនមាយ ឃុំស្តៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។

៦- សាលក្រមព្រហ្មទណ្ឌលេខ ៨៧(ជ) ចុះថ្ងៃទី២៥-មិថុនា-២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង មានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៩៦ ចុះថ្ងៃទី២០-កក្កដា-២០០៩ របស់ជនជាប់ចោទឈ្មោះ សួន ខេមរិន្ទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៧(ជ) ចុះថ្ងៃទី២៥-មិថុនា-២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការ ។

៣- អោយបន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤- សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវី នូ ចន្ថា ការពារសិទ្ធិអោយជនជាប់ចោទ កំបាំងមុខជនជាប់ចោទនិងដើមបណ្តឹង ។

បើកផ្លូវប្តឹងទាស់ និងប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ច គ្រប់ថ្នាក់ គ្រប់តំណែង និងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្ត សាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា អ៊ឹង ភូលីណែត | ហត្ថលេខា តាំង ស៊ុនឡាយ , ចាយ ច័ន្ទតារាវណ្ណ | ហត្ថលេខា អ៊ុំ សារិទ្ធ |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី..... ខែ 3...... ឆ្នាំ២០១4

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

ក្រឡាបញ្ជី

យូ_ប៊ុនឡេង

អ៊ឹង_ភូលីណែត